**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ និង**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ០១៤...សណន

**សេចក្តីណែនាំបន្ថែម**

**ស្តីពី**

**នីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណ**

**បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

**អាណត្តិទី៤ ឆ្នាំ២០១៧**

- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤
- យោងសេចក្តីណែនាំរួមលេខ ០១៨ សណន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
- យោងតាមសំណូមពរចាំបាច់នៃការងារ។

ដោយមើលឃើញ អំពីការលំបាកបស់ប្រជាពលរដ្ឋក្នុងការស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត និងក្នុងគោលបំណងជួយសម្រួលដល់ប្រជាពលរដ្ឋ ដែលប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណក្នុងការចុះឈ្មោះបោះឆ្នោត ក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៦ មានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បោះឆ្នោត ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមធ្វើការណែនាំអនុវត្តនីតិវិធីបន្ថែមអំពីការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ដូចខាងក្រោម ៖

- ប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ដោយប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងមានឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៦ ហើយមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អាចយកឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត យកទៅជួបគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ផ្ទាល់ខ្លួន ដោយស្នើសុំឱ្យ គឃ.សប បញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទផ្តល់សុពលភាព

នៅលើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ដើម្បីប្រើក្នុងការបោះឆ្នោត។

- គឃ.សប ត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្នុងបញ្ជីបោះឆ្នោត និងភិនភាគសាមីអ្នកស្នើសុំ ឱ្យបានច្បាស់លាស់មុននឹងសម្រេចចារបញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទផ្តល់សុពលភាពឱ្យប្រើប្រាស់ជាផ្លូវការ។
- គឃ.សប ត្រូវធ្វើរបាយការណ៍ចំនួន ០២(ពីរ)ច្បាប់ អំពីការចារបញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតលើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ដើម្បីប្រើក្នុងការបោះឆ្នោត ហើយបិទផ្សាយ ០១(មួយ)ច្បាប់ នៅទីស្នាក់ការ គឃ.សប និង ០១(មួយ)ច្បាប់ផ្ញើជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ជាបន្ទាន់ស្របពេលការបញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោតទៅ គ.ជ.ប។
- ការស្នើសុំ និងការបញ្ជាក់លើឯកសារបញ្ជាក់អត្តសញ្ញាណនេះ ត្រូវបញ្ចប់ត្រឹមថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង ៥:៣០នាទីល្ងាច ជាកំហិត។

ក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ស្មៀនឃុំ សង្កាត់ មេភូមិ រួមនឹង គឃ.សប ត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ភូមិរបស់ខ្លួនអំពីខ្លឹមសារនៃសេចក្តីណែនាំរួមបន្ថែមនេះ។

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អភិបាលក្រុង ស្រុក ខណ្ឌ អគ្គលេខាធិការ គ.ជ.ប គធ.ខប គឃ.សប ត្រូវចាត់ចែងផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងណែនាំអនុវត្តសេចក្តីណែនាំរួមបន្ថែមនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រធាន

ស៊ិក ប៊ុនហុក